# របាយការណ៍សកម្មភាពការងារប្រចាំខែមីនា ឆ្នាំ ២០១៧ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

I. **ស្ថានភាពទូទៅ**

II. នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានមន្ត្រីសរុបចំនួន ១៨ រូប (ស្រី ០៥ រូប) ក្នុងនោះមន្ត្រីកម្មសិក្សា ចំនួន ០២ រូប (ស្រី ០១ រូប) ÷

- ចំនួនមន្ត្រីរាជការ ដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ÷ គ្មាន
- ចំនួនមន្ត្រីរាជការ ដែលបានទៅបំពេញបេសកកម្មនៅក្រៅប្រទេស ÷ ០១រូប
  ចំនួនមន្ត្រីរាជការ សម្រាកលំហែមាតុភាព គ្មាន
- ចំនួនឈឺ ÷ ០១រូប
- ចំនួនមន្ត្រីរាជការ ដែលបានសហប្រតិបត្តិការជាមួយអង្គការ និងកម្មវិធី ÷ គ្មាន

III. **លទ្ធផលការងារ**

1. **ការងារសវនកម្ម**

– ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី និងមិនមែនកម្មវិធីឆ្នាំ ២០១៦-២០១៧និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋ **នៅមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ០៣** រួមមាន ខេត្តព្រះវិហារ ឧត្តរមានជ័យ និងខេត្តសៀមរាប ។

2. **ការងារប្រជុំ និងបណ្តុះបណ្តាល**

ថ្នាក់ដឹកនាំ និងមន្ត្រី បានចូលរួមកិច្ចប្រជុំចំនួន ០៥ លើក សិក្ខាសាលាចំនួន ០ លើក និងបណ្តុះបណ្តាលចំនួន ០ លើក÷

- **ការងារប្រជុំ**

– ប្រធាននាយកដ្ឋាន និងមន្ត្រី សរុបចំនួន ០៧ រូប ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអំពីដំណើរការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី ០៦ ខែមីនា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣

– ប្រធាននាយកដ្ឋាន ចូលរួមប្រជុំពិនិត្យឡើងវិញការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៦ និងទិសដៅឆ្នាំ ២០១៧ នៅថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០១

– ប្រធាននាយកដ្ឋាន និងប្រធានការិយាល័យ សរុបចំនួន ០២ រូប ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងពិនិត្យការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣

– ប្រធាននាយកដ្ឋាន ចូលរួមប្រជុំ កែសម្រួលផែនការសកម្មភាពរួមដំណាក់កាលទី ៣ (២០១៧-២០១៩) និងរបាយការណ៍លទ្ធផលផែនការសកម្មភាពត្រីមាសទី ៤ និងប្រចាំឆ្នាំ ២០១៦ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០១

– ប្រធាននាយកដ្ឋាន ចូលរួមប្រជុំស្តីពីដំណើរការរៀបចំប្រលងជ្រើសរើសមន្ត្រីក្របខណ្ឌឆ្នាំ ២០១៧ នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣ ។

- **សិក្ខាសាលា**

– គ្មានសកម្មភាព

- **បណ្តុះបណ្តាល**

– គ្មានសកម្មភាព

3. **កម្មវិធីផ្សេងៗ**

- អនុប្រធាននាយកដ្ឋាន ០១ រូប និងមន្ត្រី (ស្រ្តី ០៣ រូប ) ចូលរួមក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ ២០១៧ ខួបលើកទី ១០៦ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១៧ នៅភោជនីយដ្ឋាន ទន្លេបាសាក់ ២ ។